# របាយការណ៍បូកសរុបលទ្ធផលក្រុមការងារយេនឌ័រ
# ក្រសួងអភិវឌ្ឍន៍ជនបទ ប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣

## សេចក្តីផ្តើម

ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំអនុវត្តន៍ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១៩-២០២៣ ឲ្យស្របទៅតាមអាណត្តិរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅចូលរួមចំណែកលុបបំបាត់វិសមភាពយេនឌ័រក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងសំដៅចូលរួមលើកកម្ពស់សិទ្ធិមនុស្ស និងកាត់បន្ថយភាពក្រីក្រ ជាពិសេសដើម្បីលើកកម្ពស់ជីវភាពស្ត្រី និងគ្រួសារពួកគាត់ឲ្យបានល្អប្រសើរ ។ តាមរយៈក្រុមការងារយេនឌ័រ ក្រសួងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយអំពីទស្សនៈយេនឌ័រ អនុសញ្ញា ស៊ី-ដ ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ទប់ស្កាត់អំពើហឹង្សាលើស្ត្រី ។

## I. សមិទ្ធផលសម្រេចបាន

### ១. ការពង្រឹងស្ថាប័ន និងកសាងសម្ថភាព

ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើការផ្សព្វផ្សាយស្តីពី ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ អនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងអនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា និងការបណ្តុះបណ្តាលអំពីចំណេះដឹងយេនឌ័រ និងការបង្កើនភាពអង់អាចសេដ្ឋកិច្ចដល់ស្ត្រីនៅតាម សហគមន៍ ដល់បណ្តាញការងារយេនឌ័រនៅតាមមន្ទីររាជធានី ខេត្ត និងទៅដល់ប្រជាជន និងអាជ្ញាធរមូលដ្ឋាន ។ជាក់ស្តែងក្រុមការយេនឌ័រក្រសួងអភិវឌ្ឍន៍ជនបទ បានចុះផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងបណ្តុះបណ្តាល ស្តីពី ទស្សនៈយេនឌ័រ និងអនុសញ្ញា CEDAW ពិធីសារតាមជម្រើស និងច្បាប់ពាក់ព័ន្ធនានា អនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប ។

ក្នុងឆ្នាំ២០២២ នេះដោយមានការយកចិត្តទុកដាក់ពីឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី យើងបានរៀបចំពិធីអបអរសាទទិវាអន្តរជាតិនារី ៨ មីនា ដែលដឹកនាំដោយ**លោកជំទាវ ម៉ាត់ ម៉ារ៉ា** បានចុះជួបសំណេះសំណាល សួរសុខទុក្ខ បងប្អូនមន្ត្រីរាជាការជាស្ត្រី តាមនាយកដ្ឋាន មួយៗប្រកបដោយភាពស្និទ្ធស្នាល និងបាននាំយកនូវថវិការបស់ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី លើកទឹកចិត្តដល់មន្ត្រីរាជការជាស្ត្រី នូវថវិកាម្នាក់ ២០ ម៉ឺនរៀល ។

II. **បញ្ហាប្រឈម**

នាពេលកន្លងមកនេះ ក៏ដូចជាសមិទ្ធផលសម្រេចបាន ឆ្នាំ២០២២ របស់ក្រុមការងារយេនឌ័រ ទទួលបានជោគជ័យ ក្នុងការទទួលបានថវិកាជាតិ ដើម្បីអនុវត្តការងារបញ្ជ្រាបយេនឌ័ររបស់ខ្លួនមែន ប៉ុន្តែថវិកានេះនៅមានកម្រិតនៅឡើយ មិនទាន់សមស្របទៅនឹងតម្រូវការជាក់ស្តែងក្នុងការបង្កើន សមភាពយេនឌ័រនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ ជាពិសេសក្នុងបរិបទនៃការរាតត្បាត នៃជំងឺកូវីដ-១៩ ដែលត្រូវកាត់បន្ថយថវិកា បណ្តាលជះឥទ្ធិពលលើសកម្មភាពការងារ ។ ម្យ៉ាងវិញទៀតបើទោះបីជា មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង តែគម្រោងខ្លះមិនទាន់មានភាពរលូនក្នុងកិច្ចសហការ ដែលក្រុម ការងារយេនឌ័រមិនសូវទទួលបានព័ត៌មាន ថាតើគម្រោងបានបញ្ចូលផែនការសកម្មភាពរបស់ខ្លួនជាមួយ នឹងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ក្រសួងបានកម្រិតណា ។ សមត្ថភាពក្រុមការងារយេនឌ័រ នូវមានកម្រិត លើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីដឹងថាតើការអនុវត្តន៍ផែនការយុទ្ធ សាស្ត្រ មានភាពរីកចម្រើនសមស្របទៅតាមផែនការគ្រោងទុក ។

III.**ទិសដៅការងារឆ្នាំ២០២២**

- បន្តសិក្ខាសាលាផ្សព្វផ្សាយទស្សនៈយេនឌ័រ និងអនុសញ្ញា CEDAW ពិធីសារតាមជម្រើ និងច្បាប់ពាក់ព័ន្ធដល់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត និងនៅតាមសហគមន៍
- បន្តផ្សព្វផ្សាយអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- បន្តផ្សព្វផ្សាយបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅតាមសហគមន៍ជនបទ

**សេចក្តីសន្និដ្ឋាន**

នៅក្នុងឆ្នាំ ២០២២ ក្រុមការងារយេនឌ័រក្រសួងអភិវឌ្ឍន៍ បានខិតខំយ៉ាងសកម្ម ក្នុងការពិនិត្យ លើចំណុចអាទិភាព ដែលអនុវត្តន៍បន្ត លើការងារបញ្ជ្រាបយេនឌ័រ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ក្រោយ ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យ អភិវឌ្ឍន៍ជនបទ ក៏ដូចជាចំណុចខ្វះខាតនានា ដែលត្រូវដោះស្រាយ ក្នុងគោលដៅពង្រឹងចំណេះដឹង ដល់បុរស និងស្ត្រីអោយយល់ដឹងបន្ថែម ដើម្បីកាត់បន្ថយនូវគម្លាតយេនឌ័រ អំពើហឹង្សា ពង្រឹងភាព អង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី រួមចំណែកក្នុងការលើកស្ទួយជីវភាពគ្រួសារ ។